# ត្រៃប្រណាមសង្ខេប

## ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រៃ

អិមេហិ ទីបធូបា ទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ

មាតាបិតាទីនំ គុណវន្តានញ្ចទីឃរត្តំអត្ថាយ ហិតាយ សុខាយ ។

ប្រែថាខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាម្ចាស់ ដោយគ្រឿ ងសក្ការៈទាំងឡាយ មានទៀន និងធូបជាដើមនេះ ដើម្បីជាប្រយោជន៍ដើម្បីសេចក្តី សុខដល់អ្នកដ៏មានគុណទាំងឡាយ មាន មាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង។

## ពុទ្ធរតនប្បណាម

## ថ្វាយបង្គំព្រះពុទ្ធរតនៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ប្រែថា រីកិរិយាថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គអិតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។

## សូត្របាលីបីចប់ សំរាយតែមួយចប់ក៏បាន។

យោ សន្និសិន្នោ វរពោធិមូលេ មារំ សសេនំមហាតឹ វិជេយ្យា

សម្ពោធិមាគច្ឆិ អនន្តញាណោ លោកុត្តមោ តំ បនមាមិ ពុទ្ធំ

ប្រែថា  ព្រះសម្មាសម្ពុទ្ធអង្គអែណាទ្រង់គង់ចំរើននូវព្រះអានាបានស្សតិ កម្មដ្ឋានលើរតនបល័ង្គក្រោម

ម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនា ដ៏ច្រើនហើយទ្រង់ត្រាស់ដឹងនូវសម្មាស

ម្ពោធិញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ

នូវព្រះសម្មាសម្ពុទ្ធអង្គ នោះដោយគោរព។

## ថ្វាយបង្គំម្តង

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតាបច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា។

ប្រែថា ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គអែណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គអែណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុង កាលខាងមុខនេះក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គអែណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រក័ល្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះគ្រប់កាលទាំងពួង។

## ក្រាបថ្វាយបង្គំម្តង

### រួចហើយតាំងចិត្តរលឹកដល់ពុទ្ធគុណ១០ព្រះនាម ដោយបង្អោនកាយវាចាថា

អិតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ

លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ។

ប្រែថា អិតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថាអរហំព្រោះ ព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺ កិលេសព្រមទាំងវាសនាគឺកាយបយោគ និង វិចីយបយោគ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថាសម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ អិតមានគ្រូអាចារ្យណាប្រដៅ ព្រះអង្គឡើយ វិជ្ជាចរណសម្បន្នោ ទង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ និងវិជ្ជា៨ និងចរណ១៥ សុគតោ ទ្រង់ព្រះនាម ថាសុគតោ ព្រោះព្រះអង្គ មានដំណើរល្អយាងទៅកាន់សុន្ទរឋាន គឺអមតមហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក អនុត្តរោទ្រង់ព្រះ នាមថាអនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន បុរិសទម្មសារថិ ទ្រង់ព្រះនាមថាបុរិសទម្មសារថិ ព្រោះព្រះអង្គ អ្នកទូន្មាននូវ បុរស

បុគ្គល ដែលមានអុបនិស្ស័យគួរនឹងទូន្មានបាន សត្ថាទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយពុទ្ធោទ្រង់ព្រះនាមថាពុទ្ធោព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយ ញ៉ាំងអ្នកដទៃអោយត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាមថាភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រលប់កើតទៀតឡើយ។

រលឹកដល់ពុទ្ធគុណរួចហើយ គួរប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា

នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ អេតេន សច្ចវជ្ជេន ហោតុមេ ជយមង្គលំ

ប្រែថា នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ ពុទ្ធោ មេ សរណំ វរំ មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា អេតេន សច្ចវជ្ជេន ហោតុមេ ជយមង្គលំ សូមសិរីសួស្តីជ័យមង្គលចូរមានដល់ ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

ប្តេជ្ញាដូច្នេះហើយ គប្បីសូត្រខមាទោសនឹងព្រះពុទ្ធជាម្ចាស់ថា

អុត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ

អុត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏អុត្តមគឺត្បូង ពុទ្ធេ យោខលិតោទោសោ ទោសអែណាដែលខ្ញុំព្រះករុណាធ្វើអោយភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធ ពុទ្ធោ ខមតុ តំ មមំ សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

ក្រាបថ្វាយបង្គំម្តង

ធម្មរតនប្បណាម

ថ្វាយបង្គំធម្មរតនៈ

អដ្ឋង្គិការិយមថោ ជនានំ មោក្ខប្បវេសាយ អុជូ ចមគ្គោ

ធម្មោអយំ សន្ទិក រោ បណីតោ និយ្យានិកោ តំបនមាមិ ធម្មំ។

ប្រែថា ព្រះសទ្ធម្មអែណា ជាធម៌ប្រកបដោយអង្គ៨ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វានអោយចូលទៅកាន់ព្រះនិព្វានបានព្រះធម៌នេះជាធម៌ធ្វើអោយត្រជាក់រំងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេសជាធម៌ដ៏អុត្តម ជាគុណញ៉ាំងសត្វអោយចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះដោយគោរព។

## ក្រាបថ្វាយបង្គំម្តង

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតាបច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា។

ប្រែថា ព្រះធម៌ទាំងឡាយអែណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយអែណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខនេះក្តី ព្រះធម៌ទាំងឡាយអែណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង។

## រួចហើយគប្បីតាំងចិត្តរលឹកដល់ធម្មគុណដោយបង្អោនវាចាថា

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ អេហិ

បស្សិកោ អោបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ។

ប្រែថា ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌គឺព្រះត្រៃបីដកជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ធម្មោ ព្រះនព្វលោកុត្តរធម៌មាន ៩ប្រការ គឺមគ្គ៤ផល៤ និព្វាន១ សន្ទិដ្ឋិកោ ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិតដោយបច្ចវេក្ខណញាណ គឺថានឹងបាន ដឹងដោយស្តាប់ដោយជឿបុគ្គលដទៃនោះៗ ក៏ទេដែរ គឺឃើញច្បាស់ដោយខ្លួនអែង អកាលិកោជាធម៌អោយនូវផលមិន រង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានយឺនយូរឡើយ អេហិបស្សិកោ ជាធម៌គួរដល់អេហិបស្សវិធី គឺថាកាលបើព្រះអរិយបុគ្គល ដែលបានសំរេចមគ្គផលហើយក៏គួរនិងហៅបុគ្គលដទៃអោយចូលមកមើលបាន អោបនយិកោ ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោន

ចូលមក ទុកក្នុងខ្លួនដោយអំណាចនៃភាវនា បច្ចត្តំ វេទិតព្វោវិញ្ញូហី ជាធម៌គឺប្រាជ្ញទាំងឡាយ មានអុគ្ឃ ដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន។

រលឹកដល់ព្រះធម្មគុណដូច្នេះរួចហើយ គប្បីប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា

នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំវរំអេតេន សច្ចវជ្ជេន ហោតុមេ ជយមង្គលំ

ប្រែថា នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ ធម្មោមេស រណំ វរំ មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំ ព្រះករុណា អេតេន សច្ចវជ្ជេនហោតុមេ ជយមង្គ លំ សូមសិរីសួស្ដីជ័យមង្គលចូរ មានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

អុត្តមំង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេយោខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ

អុត្តមំង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិ យត្តិធម៌និងព្រះនព្វលោកុត្តរធម៌ដោយអវយវៈដ៏អុត្តមគឺត្បូង ធម្មេយោខលិតោ ទោសោ ទោសអែណា ដែលខ្ញុំព្រះករុណាធ្វើអោយភ្លាំងភ្លាត់ ហើយក្នុងព្រះធម៌ជាម្ចាស់ ធម្មោ ខមតុ តំ មមំ សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

ក្រាបថ្វាយបង្គំម្ដងសង្ឃរតនប្បណាម

ថ្វាយបង្គំព្រះសង្ឃរតនៈ

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ សព្វមលប្បហីនោ

គុណេហិនេកេហិ សមិទ្ធិបត្តោ អនាសវោ តំ បនមាមិ សង្ឃំ។

ប្រែថា ព្រះអរិយសង្ឃអែណាដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរមាន អិន្ទ្រីរំងាប់បង់ហើយ មានមន្ទិលគឺរាគាទិកិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសំរេចដោយគុណ ទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វា

យបង្គំនូវព្រះអរិ យសង្ឃនោះដោយគោរព។

## ថ្វាយបង្គំម្តង

យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតាបច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា។

ប្រែថា ព្រះសង្ឃទាំងឡាយអែណា ដែលជាសង្ឃបានសំរេចមគ្គផល និព្វានកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយអែណា ដែលជាសង្ឃនឹងបានសំរេចមគ្គផលក្នុងកាលខាងមុខនេះក្តី ព្រះសង្ឃទាំងឡាយអែណា ដែលជាសង្ឃបានសំរេចមគ្គផល ក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង។

## រួចហើយគប្បីតាំងចិត្តរលឹកដល់សង្ឃគុណដោយបង្អោនវាចាថា

សុបដិបន្នោ ភគវតោ សាវកសង្ឃោ អុជុបដិបន្នោភគវតោ សាវកសង្ឃោ ញាយ

បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិ

ទំចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា អេស ភគវតោ សាវកសង្ឃោអានុនេយ្យោ

បានុនេយ្យោទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំលោកស្សាតិ។

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកកុត្តរធម៌ អុជុបដិបេន្នា ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា ញាយបដិបន្នោ ភគវតោសាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាស្ថានក្សេមផុតចាកទុក្ខទាំងពួង សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា យទិទំចត្តារិបុរិសយុគានិ ព្រះសង្ឃអែណា បើរាប់ជាគូនៃបុរសទាំងឡាយមាន៤គូគឺ ព្រះសង្ឃដែលបានសំរេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូមួយ សកទាគាមិមគ្គ និងសកទាគាមិផលជាគូមួយ អនាគាមិមគ្គ និងអនាគាមិផលជាគូមួយ អរហត្តមគ្គ និងអរហត្តផលជាគូមួយ អដ្ឋ បុរិសបុគ្គលា បើរាប់ជាគូនៃបុរសបុគ្គលមា

ន៨គឺ ព្រះសង្ឃដែលបានសំរាច់នូវសោតាបត្តិមគ្គ១ សោតាបត្តិផល១ សកទាគាមិមគ្គ១ សកទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១ អេសភគវតោ សាវក សង្ឃោ ព្រះសង្ឃទាំងនោះជាសង្ឃសាវកនៃព្រះដ៏មានប្រភាគ អានុនេយ្យោ លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលអុទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចំងាយចូលមកបូជា បានុនេយ្យោ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់ តែងដើម្បីញាតិនិងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយចូលមកបូជា ទក្ខិណេយ្យោ លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយចូលមកបូជា អញ្ជលិករណីយោ លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញ ក្ខេត្តំ លោកស្យាតិលោកជាបុញ្ញខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យរកខេត្តដ៏ទៃក្រៃលែងជាងគ្មាន។

### រលឹកដល់សង្ឃគុណដូច្នេះហើយ គប្បីប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា

នត្ថិ ម សរណំ អញ្ញំ សង្ឃោ ម សរណំ វរំអេតេន សច្ចវជ្ជេន ហោតុមេ ជយមង្គលំ

ប្រែថា នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរលឹកនៃ ខ្ញុំព្រះករុណាមិនមែនឡើយ សង្ឃោមេ សរណំវរំ មានតែព្រះសង្ឃជាម្ចាស់ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា អេតេន សច្ចវជ្ជេន ហោតុមេ ជយមង្គលំ សូមសិរីសួស្តីជ័យមង្គលចូរមាន ដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

អុត្តមង្គេន វន្ទេហំ សង្ឃញ្ចា ទុវិធោត្តមំ វរំ សេង្ឃយោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ

អុត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ វរំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃ១ និងអរិយសង្ឃ១ ដោយអវយវដ៏អុត្តម គឺត្បូង សង្ឃេ យោខលិ តោ ទោសោ ទោសអែណាដែលខ្ញុំព្រះករុណាធ្វើអោយ ភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់ សង្ឃោ ខមតុ តំ មមំ សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

### ក្រាបថ្វាយបង្គំម្តង

វិធីនមស្សការថ្វាយបង្គំនូវព្រះរតនត្រៃមិនចំពោះកាល និងថ្វាយបង្គំនូវព្រះរតនត្រៃក្នុងកាលទាំងបី និងសេចក្តីរលឹកគុណព្រះរតនត្រៃ និងពាក្យប្តេជ្ញាខ្លួនចំពោះព្រះរតនត្រៃ នឹងថ្វាយបង្គំខមាទោសចំពោះព្រះ

រតនត្រៃទាំង៥ន័យ ដែលបានពោលមកហើយក្នុងខាងដើមនោះ ក៏ចប់ប៉ុណ្ណេះដោយពិស្តារ។

អ្នកមានសទ្ធាប្រាថ្នានឹងនមស្សការដល់ព្រះរតនត្រៃនោះ បើមានពេលអោកាសល្មម នឹងសូត្រនមស្សការទាំងបីបទ អោយបានចប់សព្វគ្រប់ដោយសេចក្តីពិស្តារដូចបែបយ៉ាងខាងដើមនោះ ក៏ជាការឧត្តមក្រៃពេក តែបើពេលខ្លីមិនអាចនឹងសូត្រ អោយចប់សព្វគ្រប់បាន ក៏គ្រាន់តែសូត្រសេចក្តីរលឹកពុទ្ធគុណធម្មគុណ សង្ឃគុណ និងថ្វាយបង្គំ ហើយនឹងសូត្រថ្វាយសក្ការបូជា ដោយសេចក្តីសង្ខេបខ្លីៗដូចន័យខាងក្រោមនេះវិញក៏បាន។

## រតនប្បណាបបែបសង្ខេប
## ព្រមទាំងបូជាគ្រឿងសក្ការៈ

ឥតិបិ សោ ភគវា អរហំ ។ល។ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ

សិរសា នមាមិ ឥញ្ញា ពុទ្ធំ ឥមេហិសក្ការេហិ អភិបូជយាមិ។

ប្រែថា ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថាអរហំព្រោះ ព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺ កិលេសព្រមទាំងវាសនាគឺកាយបយោគ និងវិចីយបយោគ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថាសម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅ ព្រះអង្គឡើយ វិជ្ជាចរណសម្បន្នោ ទង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ និងវិជ្ជា៨ និងចរណ១៥ សុគតោ ទ្រង់ព្រះនាម ថាសុគតោ ព្រោះព្រះអង្គ មានដំណើរល្អយាងទៅកាន់សុន្ទរឋាន គឺអមតមហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក អនុត្តរោទ្រង់ព្រះ នាមថាអនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន បុរិសទម្មសារថិ ទ្រង់ព្រះនាមថាបុរិសទម្មសារថិ ព្រោះព្រះអង្គ អ្នកទូន្មាននូវ បុរសបុគ្គល ដែលមានឧបនិស្ស័យគួរនិងទូន្មានបាន សត្ថាទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយពុទ្ធោទ្រង់ព្រះនាមថាពុទ្ធោព្រោះព្រះត្រាស់ដឹងនូវចតុរារិយសច្ច ហើយ ញ៉ាំងអ្នកដទៃអោយត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាមថាភគវា ព្រោះព្រះអង្គមាន

ដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រលប់កើតទៀតឡើយ តំអរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្មា សម្ពុទ្ធ ជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណ មានគុណថា អរហំជា ដើមនោះដោ យសិរសាគឺត្បូង តញ្ចា ពុទ្ធំអិមេហិសក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណោះ។

ថ្វាយង្គំមុតង

ស្វាក្ខាតោ ភគវតា ធម្មោ ។ល។ តំស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ

សិរសា នមាមិ តញ្ចា ធម្មំអិមេហិ សក្ការេហិ អភិបូជយាមិ។

ប្រែថា ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធមិគឺព្រះត្រៃបីដកជាធមិគឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ធម្មោ ព្រះនព្វលោកុត្តរធមិមាន ៩ប្រការ គឺមគ្គ៤ផល៤ និព្វាន១ សន្ទិដ្ឋិកោ ជាធមិគឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិតដោយបច្ចវេក្ខណញាណ គឺថានឹងបាន ដឹងដោយស្តាប់ដោយជឿបុគ្គលដទៃនោះៗ ក៏ទេដែរ គឺឃើញច្បាស់ដោយខ្លួនឯង អកាលិកោជាធមិអោយនូវផល មិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានយឺនយូរឡើយ អេហិបស្សិកោ ជាធមិគួរដល់អេហិបស្សវិធី គឺថាកាលបើព្រះអរិយបុគ្គល ដែលបានសំរេចមគ្គផលហើយ ក៏គួរនិងហៅបុគ្គលដទៃអោយចូលមកមើលបាន អោបនយិកោ ជាធមិគឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមក ទុកក្នុងខ្លួនដោយអំណាចនៃភាវនា បច្ចត្តំ វេទិតព្វោវិញ្ញូហី ជាធមិគឺប្រាជ្ញទាំងឡាយ មានអុត្បដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន។ តំ ស្វាក្ខាតាទិគុណ សំយុត្តំ ធម្មំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធមិ ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថាស្វាក្ខាតាជាដើមនោះដោយសិរសាគឺត្បូង តញ្ចា ធម្មំ អិមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូម បូជាចំពោះនូវព្រះធមិជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណោះ។

ថ្វាយបង្គំម្តង

សុបដិបន្នោ ភគវតោ សាវកសង្ឃោ អុជុបដិបន្នោភគវតោ សាវកសង្ឃោ ញាយ

បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិ

ទំចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា អេស ភគវតោ សាវកសង្ឃោអានុនេយ្យោ

បានុនេយ្យោទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំលោកស្សាតិ តំសុ

បដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ញា សង្ឃំ អិមេហិ សក្ការេហិ អភិបូជយាមិ។

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកកុត្តរធម៌ អុជុបដិបេន្នា ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា ញាយបដិបន្នោ ភគវតោសាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាស្ពានក្បៀមផុតចាកទុក្ខទាំងពួង សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា យទិទំចត្តារិបុរិសយុគានិ ព្រះសង្ឃអែណា បើរាប់ជាគូនៃបុរសទាំងឡាយមាន៤គូគឺ ព្រះសង្ឃដែលបានសំរេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូមួយ សកទាគាមិមគ្គ និងសកទាគាមិផលជាគូមួយ អនាគាមិមគ្គ និងអនាគាមិផលជាគូមួយ អរហាត្តមគ្គ និងអរហាត្តផលជាគូមួយ អដ្ឋ បុរិសបុគ្គលា បើរាប់ជាគូនៃបុរសបុគ្គលមាន៨គឺ ព្រះសង្ឃដែលបានសំរាច់នូវសោតាបត្តិមគ្គ១ សោតាបត្តិផល១ សកទាគាមិមគ្គ១ សកទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១ អេសភគវតោ សាវក សង្ឃោ ព្រះសង្ឃទាំងនោះជាសង្ឃសាវកនៃព្រះដ៏មានប្រភាគ អានុនេយ្យោ លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលអុទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចំងាយចូលមកបូជា បានុនេយ្យោ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់ តែងដើម្បីញាតិនិងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយចូលមកបូជា ទក្ខិណេយ្យោ លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយចូលមកបូជា អញ្ជលិករណីយោ លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញ ក្ខេត្តំ លោកស្សាតិលោកជាបុញ្ញខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យរកខេត្តដ៏ទៃក្រៃលែងជាងគ្មាន តំសុបដិបន្នាទិគុណសំយុត្តំ សង្ឃំសិរ សានមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយ ដោយគុណ មានគុណថាសុបដិបន្នោជាដើមនោះ ដោយសិរសាគឺត្បូង តញ្ញា សង្ឃំ អិមេហិ សក្ការេហិ អភិបូជយាមិខ្ញុំ ព្រះករុណាសូមបូជាចំពោះនូវ

ព្រះសង្ឃ ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡា យមានប្រមាណប៉ុណ្ណោះ។

## ក្រាបថ្វាយបង្គំម្តង

នមស្សការយ៉ាងសង្ខេប

នមោ តស្សារហន្តស្ស ភគវន្តស្ស តាទិនោ សម្មា សាមំ វពុទ្ធស្ស ធម្មេវិភជ្ជវាទិនោ។

ប្រែថា នមោ តស្សារហន្តស្ស ភគវន្តស្ស តាទិនោ កិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូលមានដល់ព្រះដ៏មានព្រះភាគជាម្ចាស់ សម្មា សាមំ វពុទ្ធស្ស ធម្មេវិភជ្ជវាទិនោ ព្រះអង្គត្រាស់ដឹងនូវធម៌ គឺបុគ្គលគប្បីដឹងដោយប្រពៃចំពោះព្រះអង្គពិត ហើយទ្រង់សំដែងញែកចែកនូវធម៌ទាំងលាយនោះដល់សព្វសត្វទាំងពួង។

នមោ តស្សេវ ធម្មស្ស និយ្យានិកស្ស វដ្តតោ បភេទា នវ វិធស្ស ស្វាក្ខាតស្សេវ សច្ចតោ។

នមោ តស្សេវ ធម្មស្ស និយ្យានិកស្ស វដ្តតោ កិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះធម៌ជាម្ចាស់នោះ ជាធម៌មានគុណជាទីស្រោចស្រង់នូចសត្វអោយចេញចាកវដ្តសង្សារ បភេទា នវ វិធស្ស ស្វាក្ខាតស្សេវ សច្ចតោ ជាធម៌ប្រភេទមាន៩ប្រការ មានសោតាបត្តិមគ្គជាដើម មានព្រះនិព្វានជាទីបំផុតដែលព្រះសម្ពុទ្ធសំដែងទុកមកហើយដោយប្រពៃមែនពិត។

## ក្រាបថ្វាយបង្គំម្តង

នមោ អរិយសង្ឃស្ស សញ្ជាភូតស្ស សត្ថុនោ កិលេសានុសយេ សព្វេ បហានប្បដិបត្តិយា។

ប្រែថា នមោ អរិយសង្ឃស្ស សញ្ជាភូតស្ស សត្ថុនោ កិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះអរិយសង្ឃជាម្ចាស់នោះ ជាព្រះសង្ឃកើតហើយក្នុងពួកសាវកនៃព្រះសាស្តា កិលេសានុសយេ សព្វេ បហានប្បដិបត្តិយា ជាព្រះសង្ឃប្រតិបត្តិដើម្បីលះបង់នូវលាមកធម៌ទាំងឡាយទាំងពួង ដែលជាធម៌រមែងផ្តេកផ្តួលទៅតាមកិលេសជាគ្រឿងញ៉ាំងចិត្តសន្តាននៃសត្វទាំងពួងអោយសៅហ្មង។

## នមស្សការយ៉ាងសង្ខេប

វិសុទ្ធករុណាញាណំ ពុទ្ធំ សម្ពុទ្ធបូជិតំ ធម្មំ សទ្ធម្មសម្ភូតំ វន្ទេ សង្ឃំ និរង្គណំ។

ប្រែថា ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គមានព្រះហរិទ័យករុណាដល់សត្វដទៃ គឺថាទ្រង់បៀតបៀននូវកងទុក្ខដែលមានក្នុងសន្តាននៃសត្វដទៃ ដោយព្រះញាណ ពោលគឺព្រះអរហត្តមគ្គដ៏ម៉ត់ចត់ស្អាតចាកមន្ទិលគឺរាគទិក្កិលេស សូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ គឺព្រះសម្ពុទ្ធបូជាហើយ គឺថាព្រះអង្គសំដែងហើយ សូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដែលកើតដោយអរិយជាតិព្រោះព្រះសទ្ធម្មជាអ្នកមិនមានដំណើរទៅកាន់ភាវទាបគឺកិលេសឡើយ។

## ក្រាបថ្វាយបង្គំម្តង

## នមស្សការយ៉ាងសង្ខេប

នមេ ពុទ្ធំ តិលោកគ្គំ ញេយ្យសាគរបរគុំ ភវាភវកំ ធម្មំ គណាញ្ច គុណសាគរំ។

ប្រែថា ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្ពុទ្ធជាម្ចាស់ ព្រះអង្គជាបុគ្គលប្រសើរលើសសត្វក្នុងត្រៃលោក ព្រះអង្គមានញាណ គឺគុណសំរាប់ដឹងនូវញេយ្យធម៌ទាំងពួងដ៏ជ្រាលជ្រៅ បីដូចជាសាគរធំ ព្រះអង្គមានដំណើរទៅដល់ហើយនូវត្រើយសាគរគឺញាណនៃព្រះអង្គផង ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ គឺគុណសំរាប់ទ្រទ្រង់នូវសត្វទាំងឡាយ ដែលជាអ្នកប្រតិបត្តិដ៏សមគួរតាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាជាម្ចាស់ មិនអោយធ្លាក់ចុះទៅក្នុងអបាយភូមិទាំងឡាយផង ភវាភវករំ ជាគុណតែងធ្វើនូវកម្មភព គឺកុសលាកុសលចេតនា២៩ មានកុសលចេតនាជាដើម និងអុបបត្តិភពទាំង៩ មានកាមភពជាដើម ដែលកើតអំពីបច្ច័យ គឺកម្មភពអោយវិនាសសាបសូន្យទៅផង ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះអរិយសង្ឃលោក មានគុណដ៏ជ្រាលជ្រៅបីដូចជាសាគរផង។

## នមស្សការពាក្យកាព្យ

បញ្ចូលបន្ថែមពុំមានក្នុងគិហិទេ

ខ្ញុំសូមនមស្សការ លើកហត្ថាអោនសិរសី

| | |
|---|---|
| បង្គំគុណទាំង៣ | ឆ្ពោះលើសលុបត្រៃលោកា |
| សូមបុណ្យកងកុសល | ចូរមានដល់យើងខ្ញុំណា |
| ពេញបូរណ៌ស្មាធារា | ដូចជលសាធំទូលាយ |
| សូមអោយកំចាត់បង់ | អពមង្គលទាំងឡាយ |
| អោយជៀសចេញចាកឆ្ងាយ | ក្តីអន្តរាយកុំបីមាន |
| ដោយកំលាំងអានុភាព | បុញ្ញលាភជាប្រធាន |
| កងបុញ្ញរាសីមាន | សូមបានក្សាន្តកុំមានមោះ |
| ដោយគុណនមស្សក្កា | ត្រៃរតនាប្រសើខ្ពស់ |
| សូមអានិសង្សនោះ | ដាក់ដល់ស្ថាននិព្វានហោង |

## ពាក្យពោលប្រកាសសូមសេចក្តីល្អ សេចក្តីចំរើនគ្រប់យ៉ាង

ហោតុសព្វំ សុមង្គលំ រក្ខន្តអ សព្វទេវតា សព្វពុទ្ធា «សព្វធម្មា សព្វសង្ឃា»នុភាវេន សោត្ថិ ហោតុនិរន្តរំ។

ហោតុសព្វំ សុមង្គលំ សុមង្គលគឺសេចក្តីចំរើនគ្រប់យ៉ាងចូរមានដល់ខ្ញុំ រក្ខន្តុ សព្វ ទេវតា ទេវតាទាំងពួង ទាំងឡាយចូររក្សានូវខ្ញុំ សព្វពុទ្ធានុភាវេន ដោយអានុភាពនៃ ព្រះពុទ្ធគ្រប់ព្រះអង្គ សព្វធម្មានុភាវេនដោយ អានុភាពនព្រៃះធម៌ទាំងពួង សព្វសង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំងពួង សោត្ថិ ហោតុនិរន្តរំ សូមសេរីសួស្តីចូរមានដល់ខ្ញុំ អោយបានគ្រប់ពេលកុំបីមានចន្លោះឡើយ។

## ចប់ត្រៃប្រណាមដោយសង្ខេបតែប៉ុណ្ណោះ